**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៨៧...សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួលរៀបចំ ខ្លឹមសារសម្រាប់កិច្ចប្រជុំលើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ រវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំលើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ឪ ច័ន្ទ្រផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងការពារជាតិ | | អនុប្រធាន |
| ៤- អនុប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន | | សមាជិក |

៩- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៦- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល សមាជិក

៧- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៨- រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៩- រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

១០- រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១១- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១២- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

១៣- អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៤- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១៥- ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៦- ឯកឧត្តម **ប្រាក់ សំអឿន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិក

១៧- ឯកឧត្តម **សេង យូអ៊ាន់** អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ សមាជិក

១៨- ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សមាជិក

១៩- ឯកឧត្តម នាយឧត្តមសេនីយ៍ **គង សុខន** អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិក

២០- ឯកឧត្តម **ជាម ច័ន្ទសោភ័ណ្ឌ** អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ សមាជិក

២១- ឯកឧត្តម **ជា សុមេធី** អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង សមាជិក

២២- ឯកឧត្តម **ម៉ែន វិបុល** អភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង សមាជិក

២៣- ឯកឧត្តម **ម៉ៅ ធិនុណា** អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល សមាជិក

២៤- ឯកឧត្តម **អ៊ា ថន** អភិបាល នៃគណៈអភិបាលខេត្តក្រចេះ សមាជិក

២៥- ឯកឧត្តម **អ៊ូច តា** អភិបាល នៃគណៈអភិបាលខេត្តតាកែវ សមាជិក

២៦- ឯកឧត្តម **យន្ត មីន** អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ សមាជិក

២៧- ឯកឧត្តម **ស្វាយ សំអ៊ាង** អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី សមាជិក

២៨- ឯកឧត្តម **ថង សាវុន** អភិបាល នៃគណៈអភិបាលខេត្តរតនគិរី សមាជិក

២៩- ឯកឧត្តម **ជាវ តាយ** អភិបាល នៃគណៈអភិបាលខេត្តកំពត សមាជិក

៣០- ឯកឧត្តម **កែន សត្ថា** អភិបាល នៃគណៈអភិបាលខេត្តកែប សមាជិក

៣១- ឯកឧត្តម **សួស ប្រាថ្នា** អគ្គនាយករងទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត សមាជិក

**ប្រការ ២.-**

ក្រុមការងារខាងលើនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងបណ្តាខេត្តកម្ពុជា ដែលជាប់ព្រំដែនជាមួយប្រទេសវៀតណាម ដើម្បីរៀបចំខ្លឹមសារកិច្ចប្រជុំលើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែននេះឱ្យបានគ្រប់ជ្រុងជ្រោយស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- ពិភាក្សា និងសម្របសម្រួលជាមួយក្រុមការងារវៀតណាម ដើម្បីរៀបចំខ្លឹមសារ និងកិច្ចការនានាឱ្យបានសមស្របសម្រាប់កិច្ចប្រជុំលើកទី១០ នេះ
- រៀបចំគម្រោងថវិកាចំណាយនានាពាក់ព័ន្ធនឹងកិច្ចប្រជុំ
- ធានាឱ្យដំណើរការនៃកិច្ចប្រជុំប្រព្រឹត្តទៅមានភាពរលូន និងទទួលបានលទ្ធផលល្អប្រសើរ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រមុខរាជរដ្ឋាភិបាល។

**ប្រការ ៣.-**

ក្នុងការអនុវត្តការងារ ប្រធានក្រុមការងារអន្តរក្រសួងត្រូវសុំយោបល់ដឹកនាំផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួង ត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានក្រុមការងារអន្តរក្រសួង។

**ប្រការ ៤.-**

ក្រុមការងារអន្តរក្រសួងអាចមានក្រុមការងារមួយចំនួនជាជំនួយការ ដែលកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ប្រធានក្រុមការងារអន្តរក្រសួងអាចស្នើសុំមន្ត្រីនៃទីស្តីការក្រសួងមហាផ្ទៃ ឬមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងក្រុមការងារអន្តរក្រសួង ឱ្យជួយការងារតាមការចាំបាច់ តាមការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីនៃក្រសួង ឬប្រធានស្ថាប័នពាក់ព័ន្ធទាំងនោះ។

**ប្រការ ៥.-**

ក្នុងការសម្របសម្រួលរៀបចំខ្លឹមសារនៃកិច្ចប្រជុំ ក្រុមការងារអន្តរក្រសួងមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យចូលរួមតាមការចាំបាច់។

**ប្រការ ៦.-**

ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងមហាផ្ទៃក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៧.-**

ក្រុមការងារអន្តរក្រសួងបញ្ចប់កិច្ចការរបស់ខ្លួន បន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាលរួចរាល់ជាស្ថាពរ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អភិបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម និងឯកឧត្តម ដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ